Australian Government
Department of Social Services



# អំពើហិង្សាតាមផ្ទះ និងក្នុងគ្រួសារ

## នៅប្រទេសអូស្ត្រាលី អំពើហិង្សាតាមផ្ទះ និងក្នុងគ្រួសារ មិនអាចទទួលយកបានទេ។

អំពើហិង្សាតាមផ្ទះ និងក្នុងគ្រួសារ គឺជាបទល្មើសប្រឆាំងនឹងច្បាប់។

ជនណាដែលប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះ អាចជាប់ពន្ធនាគារ ទោះបីអ្នកនោះជាបុរស ឬស្ត្រីក៏ដោយ។

ប្រសិនបើអ្នក ឬជនណាម្នាក់ដែលអ្នកស្គាល់ស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ សូមទូរស័ព្ទទៅប៉ូលីសលេខ **000**។

ប៉ូលីសនៅប្រទេសអូស្ត្រាលីមានសុវត្ថិភាព ហើយអាចទុកចិត្តបាន។

សម្រាប់ការប្រឹក្សាយោបល់ និងការផ្តល់ព័ត៌មានជាសម្ងាត់ ហើយឥតគិតថ្លៃ  សូមទូរស័ព្ទ 1800RESPECT លេខ **1800 737 732**។

ប្រសិនបើអ្នកត្រូវការអ្នកបកប្រែភាសាដោយឥតគិតថ្លៃ សូមទូរស័ព្ទលេខ **131 450**។

## នៅក្នុងស្ថានភាពបែបណាក៏ដោយ រដ្ឋាភិបាលអូស្ត្រាលីមិនអត់ឱនចំពោះអំពើហិង្សាតាមផ្ទះ និងក្នុងគ្រួសារឡើយ

អំពើហិង្សាតាមផ្ទះ និងក្នុងគ្រួសាររួមមានការប្រព្រឹត្ត ឬការគម្រាមកំហែងដែលមានបំណងដើម្បីត្រួតត្រាលើដៃគូដោយបង្កឲ្យមានការភ័យខ្លាច ឬការគម្រាមកំហែងដល់សុវត្ថិភាពរបស់ពួកគេ។ អំពើហិង្សាតាមផ្ទះ និងក្នុងគ្រួសារអាចរួមបញ្ចូល៖

- ការវាយតប់
- ការច្រេបាច់ក
- ការបដិសេធមិនឲ្យលុយដែលសំខាន់ចាំបាច់ដល់ដៃគូ ឬក្រុមគ្រួសារ
- ការមិនឲ្យដៃគូជួបក្រុមមិត្តភក្តិ និងគ្រួសារ
- ការជេរប្រមាថ ឬទិទៀនដៃគូជាប្រចាំ
- បង្ខំដៃគូដើម្បីរួមភេទ ហើយនិង
- ការគម្រាមកំហែងដល់កូនៗ ឬសត្វចិញ្ចឹម

## ស្ត្រីមានសិទ្ធិដូចបុរសដែរ

ច្បាប់ក្នុងប្រទេសអូស្ត្រាលីផ្តល់សិទ្ធិឲ្យស្មើៗគ្នាចំពោះបុរស និងស្ត្រី។

ជនគ្រប់រូបមានសិទ្ធិទទួលបានបទពិសោធន៍វិជ្ជមាន ហើយមាន ទំនាក់ទំនងសុវត្ថិភាព ជាមួយក្រុមគ្រួសារ មិត្តភក្តិ និងជនជាទីស្រឡាញ់របស់ពួកគេ។ អំពិហិង្សាមិនអាចទទួលយកបានឡើយ។  គ្មាននរណាម្នាក់គួរទទួលយកការប្រព្រឹត្តមិនល្អ ឬការធ្វើទុក្ខទោសទេ

## មានសេវាយល់ដឹងពីវប្បធម៌នៅក្នុងប្រទេសអូស្ត្រាលីដែលអាចជួយបាន

**1800RESPECT** គឺជាសេវាផ្តល់ការប្រឹក្សាអំពីការរំលោភបំពានខាងផ្លូវភេទ អំពើហិង្សាតាមផ្ទះ និងក្នុងគ្រួសារទូទាំងប្រទេសរបស់ប្រទេសអូស្ត្រាលី។ សេវានេះផ្តល់ព័ត៌មាន និងការប្រឹក្សាតាមអ៊ីនធើណិត និងទូរស័ព្ទដោយសម្ងាត់ ហើយឥតគិតថ្លៃ។ អ្នកផ្តល់ការប្រឹក្សានឹងស្តាប់អ្នក ឆ្លើយសំណួរ និងអាចបញ្ជូនអ្នកទៅកាន់សេវាជំនួយផ្សេងៗទៀតនៅតាមតំបន់ដែលអ្នករស់នៅ។

សូមទូរស័ព្ទលេខ **1800 737 732** ឬបើកចូលវិបសាយរបស់ **1800RESPECT** នៅត្រង់ **www.1800RESPECT.org.au** ។

## តើអ្នកត្រូវការអ្នកបកប្រែភាសាឬទេ?

សូមទូរស័ព្ទទៅ **សេវាបកប្រែភាសាសរសេរ និងនិយាយ** (**Translating and Interpreting Service**) (TIS) ដោយឥតគិតថ្លៃលេខ **131 450**។ TIS អាចជួយអ្នកស្វែងរកសេវាផ្សេងៗទៀតបាន ក៏ប៉ុន្តែ TIS មិនផ្តល់ការប្រឹក្សាទេ។ គ្រប់ការហៅទូរស័ព្ទទាំងអស់គឺឥតគិតថ្លៃ និងសម្ងាត់។